**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ [illegible] សហវ.[illegible]

ថ្ងៃ[illegible] ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

## ជម្រាបជូន

- **ឯកឧត្តមអនុរដ្ឋលេខាធិការ និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**
- **ឯកឧត្តមអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន**
- **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**
- **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**
- **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ**
- **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ**
- **ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍**
- **ឯកឧត្តមនាយក នៃវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**កម្មវត្ថុ:** ផែនការសវនកម្មផ្ទៃក្នុងឆ្នាំ២០២០។

**យោង:**-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៩/០២៥ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០

-បានឃើញអនុក្រឹត្យលេខ ៧៥/អនក្រ/បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៤៨៨/អនក្រ/បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៤០/អនក្រ/បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

-បានឃើញប្រកាសលេខ ១៥៤៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញប្រកាសលេខ៧៣៩ សហវ.ប្រក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃនាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មាននៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញលិខិតលេខ សហវ.អសក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីផែនការយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុង ២០២០-២០២២។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ) បានតាក់តែងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ឱ្យក្លាយជាឧបករណ៍គោលនយោបាយដ៏ស័ក្តិសិទ្ធិសម្រាប់គាំទ្រ និងធានាឱ្យកម្ពុជាបន្តទទួលបាននូវកំណើនសេដ្ឋកិច្ច ប្រកបដោយបរិយាប័ន្ន ធន់ និងមានសមត្ថភាពប្រកួតប្រជែង ក្នុងកម្រិតខ្ពស់ជាមធ្យម៧% ក្នុងមួយឆ្នាំ ដើម្បីលើកស្ទួយវិបុលភាពរបស់ប្រជាជន និងបន្តចាក់គ្រឹះសន្តិភាពឱ្យកាន់តែរឹងមាំជានិរន្តរ៍។ ប្រការនេះ ទាមទារឱ្យរដ្ឋបាលសាធារណៈត្រូវខិតខំពង្រឹងសមត្ថភាពនិងភាពវៃឆ្លាត ដើម្បីសំយោគនិងបម្លែងសក្តានុពលនៃបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ ទៅជាកម្លាំងចលករដ៏ខ្លាំងក្លា រុញច្រានរាល់ការដ្ឋាននៃការកែទម្រង់របស់រាជរដ្ឋាភិបាល ឱ្យសម្រេចបានជោគជ័យតាមការគ្រោងទុក។ ដោយឡែកចំពោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការរក្សាបាននូវចីរភាពសមិទ្ធកម្មក្នុងបីដំណាក់កាលកន្លងមក និងជោគជ័យក្នុងដំណាក់កាលទី៤ "**គណនេយ្យភាពសមិទ្ធកម្ម**" នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅឆ្នាំ២០២៥ ខាងមុខ គឺជាលក្ខខណ្ឌមិនអាចកែប្រែបាន។

ស្ថិតក្នុងបរិការណ៍នេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានណែនាំឱ្យអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង តម្រង់ទិសក្នុងការរៀបចំផែនការសវនកម្មផ្ទៃក្នុងឆ្នាំ២០២០ សំដៅរួមចំណែកគាំទ្រយ៉ាងសកម្មចំពោះលក្ខខណ្ឌមិនអាចកែប្រែបានខាងលើ។ ក្នុងន័យនេះ ផែនការសវនកម្មផ្ទៃក្នុង ឆ្នាំ២០២០ ដែលជាផែនការសវនកម្មឆ្នាំទី១ នៃផែនការយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុង២០២០-២០២២ នឹងសម្រួចការយកចិត្តទុកដាក់លើប្រព័ន្ធ (System) ដំណើរការ (Process) និងប្រតិបត្តិការ (Operation)ថ្មីៗ ជាផ្លែផ្កាកើតចេញពីការផ្តើមអនុវត្តនូវផែនការយុទ្ធសាស្ត្រសំខាន់ៗដែលជាការពន្លឿកខឿនសម្រាប់ធានាជោគជ័យដល់កិច្ចការកែទម្រង់ដំណាក់កាលចុងក្រោយរបស់ខ្លួន ក៏ដូចជាការការពារនិរន្តភាពនៃសមិទ្ធកម្មរបស់ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូលផងដែរ។ ផែនការយុទ្ធ-សាស្ត្រសំខាន់ៗ មានដូចជា: យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម២០១៩-២០២៣, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា២០១៨-២០២៥, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ២០១៩-២០២៥, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ២០១៩-២០២៥, យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ២០១៩-២០២៥ និងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ

២០១៩-២០២៣ បានជំរុញឱ្យមានការផ្លាស់ប្តូរជាសារវន្តនូវបែបផែននៃការគ្រប់គ្រង និងការអនុវត្តហិរញ្ញវត្ថុនៅផ្ទៃក្នុងនៃ កសហវ ក៏ដូចជានៅក្នុងរាជរដ្ឋាភិបាលទាំងមូល។

ទន្ទឹមនឹងការពិនិត្យលើភាពរឹងមាំនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ភាពអនុលោមនៃប្រព័ន្ធគ្រប់គ្រងនិងដំណើរការ និងភាពត្រឹមត្រូវនៃព័ត៌មានហិរញ្ញវត្ថុ ផែនការសវនកម្មផ្ទៃក្នុងឆ្នាំ២០២០ នឹងចាប់ផ្តើមវាស់វែងកម្រិតប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងសន្សំសំចៃនៃប្រតិបត្តិការជ្រើសរើសមួយចំនួន រួមទាំងការជំរុញការត្រួតពិនិត្យសុវត្ថិភាព ប្រសិទ្ធភាពប្រតិបត្តិការ និងភាពងាយស្រួលនៃការប្រើប្រាស់របស់ប្រព័ន្ធ FMIS ក៏ដូចជាប្រព័ន្ធផ្សេងៗនៅតាមបណ្តាអគ្គនាយកដ្ឋានមួយចំនួន។ ទន្ទឹមនឹងនេះ គោលបំណងសវនកម្មក៏តម្រង់ទៅរកគុណភាពរបស់ប្រព័ន្ធ ដូចជា: ភាពប្រទាក់ក្រឡា សមភាពយេនឌ័រ ការរក្សាសង្គតិភាពនិងចីរភាព ភាពសមស្រប នវានុវត្តន៍ សមធម៌និងយុត្តិធម៌ ភាពសុខដុម និងរក្សាបរិស្ថានជាដើម។ ដើម្បីបង្កើនតម្លៃសវនកម្មបន្ថែមមួយកម្រិតទៀត ការវាយតម្លៃភាពត្រឹមត្រូវនៃចម្លងការហិរញ្ញវត្ថុមួយចំនួននឹងធ្វើយ៉ាងលម្អិត។

ក្រោមលក្ខខណ្ឌមិនអាចកែប្រែ និងគោលបំណងសវនកម្មខាងលើ ផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ២០២០ បានកំណត់វិសាលភាពសវនកម្មសម្រាប់ថ្នាក់កណ្តាលមានចំនួន៨ គោលដៅ ក្នុងនោះអគ្គនាយកដ្ឋានមានចំនួន៧ និងគណកម្មាធិការចំនួន១ រួមទាំងសវនកម្មប្រព័ន្ធ FMIS នៅតាមក្រសួង ស្ថាប័នចំនួន៤ គោលដៅ ព្រមទាំងអង្គភាពក្រោមឱវាទ កសហវ នៅថ្នាក់រាជធានី-ខេត្ត ទាំង២៥ (ដូចមានបង្ហាញក្នុងផែនការភ្ជាប់មកជាមួយ)។ វិសាលភាពសវនកម្មនេះ ក៏មិនបដិសេធការត្រួតពិនិត្យតាមការចាំបាច់ លើតួនាទីនិងលទ្ធផលការងាររបស់មន្ត្រី កសហវ ដែលបានចូលរួមបំពេញភារកិច្ចនៅក្នុងយន្តការមួយចំនួន ដូចជា:គណៈកម្មាធិការ ក្រុមប្រឹក្សាភិបាល ក្រុមត្រួតពិនិត្យហិរញ្ញវត្ថុ ក្រុមការងារអន្តរក្រសួងជាដើម។ បន្ថែមលើនេះ អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងអាចចុះសវនកម្មដោយឡែក តាមការសម្រេចរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីនៃ កសហវ លើពាក្យបណ្តឹង លើសំណើរបស់អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង និងលើសំណូមពររបស់អង្គភាពក្រោមឱវាទ កសហវ ក្រៅពីការធ្វើសវនកម្មតាមផែនការសវនកម្មផ្ទៃក្នុងឆ្នាំ២០២០ នេះ។ ការចុះអនុវត្តសវនកម្មអាចប្រព្រឹត្តិទៅដោយផ្តល់ព័ត៌មានជាមុន និងមិនផ្តល់ជាមុនតាមការចាំបាច់។

ដូច្នេះ ដើម្បីធានាឱ្យផែនការសវនកម្មផ្ទៃក្នុងឆ្នាំ២០២០ អាចសម្រេចបានតាមការតម្រង់ទិស គោលបំណងក្នុងវិសាលភាពសវនកម្មខាងលើប្រកបដោយលទ្ធផលល្អប្រសើរ អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងត្រូវខិតខំអនុវត្តភារកិច្ច ដោយប្រកាន់ខ្ជាប់នូវអភិក្រមការងារទាំងបួនប្រការរបស់ កសហវ គោរពស្តង់ដានីតិវិធីសវនកម្មនិងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់សវនករផ្ទៃក្នុង និងទទួលបាននូវសិទ្ធិចូលដល់ប្រព័ន្ធ មន្ត្រី បញ្ជិកា ស្ថិតិ ទិន្នន័យ ឯកសារ ទ្រព្យសម្បត្តិ គណនី និងអាចគេស្តបញ្ជាក់ភស្តុតាងដល់ទីកន្លែងស្របតាមនីតិវិធីសវនកម្មស្តង់ដា។ ទន្ទឹមនឹងនេះ សវនដ្ឋានទាំងអស់ត្រូវផ្តល់កិច្ចសហការជិតស្និទ្ធ ដោយបង្កលក្ខណៈងាយស្រួលដល់ការអនុវត្តសវនកម្មជារួម និងជាពិសេសក្នុងការជួបពិភាក្សា ផ្តល់ព័ត៌មាន (រឹង/ទន់) ដោយសុឆន្ទៈ ទាន់ពេល និងស្មារតីទទួលខុសត្រូវខ្ពស់។ ប្រធានសវនដ្ឋានត្រូវផ្តល់ការបំភ្លឺ លើចំណុចកត់សម្គាល់ដោយសវនករឱ្យបានទាន់ពេលវេលាស្នើសុំ និងត្រូវចូល

រួមក្នុងអង្គប្រជុំសវនកម្មបើកនិងបិទ ដើម្បីក្តាប់បាននូវនីតិវិធីសវនកម្ម សំណូមពរ និងលទ្ធផលសវនកម្មដោយផ្ទាល់ និងខិតខំកែលម្អតាមអនុសាសន៍សវនកម្មដែលបានឯកភាព។

អាស្រ័យហេតុនេះ សូមឯកឧត្តមជ្រាប និងចូលរួមសហការអនុវត្តផែនការសវនកម្មផ្ទៃក្នុងឆ្នាំ២០២០ នេះ ឱ្យសម្រេចបានជោគជ័យប្រកបដោយប្រសិទ្ធភាពខ្ពស់។

សូមឯកឧត្តមទទួលនូវការរាប់អានពីខ្ញុំ។

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

<u>ចម្លងជូន:</u>

- អាជ្ញាធរសវនកម្មជាតិ "ដើម្បីជូនជ្រាប"
- សវនដ្ឋានក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ